# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍
## របៀបវារៈទីIIC: កិច្ចគាំពារសង្គមសម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះ
## ថ្លែងដោយលោក Jean-Pierre de Margerie តំណាងប្រចាំប្រទេសនៃកម្មវិធីស្បៀងអាហារពិភពលោក
## តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**ភ្នំពេញ ថ្ងៃទី ២-៣ ខែ មិថុនា ឆ្នាំ ២០១០**

*សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!*

ជាក់ស្តែងមានការរីកចំរើនយ៉ាងច្រើនគួរឱ្យកត់សំគាល់ ចាប់តាំងពីមានការប្តេជ្ញាចិត្តជាលើកដំបូងនៅក្នុងវេទិកា សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ដែលបានធ្វើឡើងកាលពីខែធ្នូ ឆ្នាំ២០០៨ សំដៅពង្រឹងកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ។ ការប្តេជ្ញាចិត្តនេះត្រូវបានធ្វើឡើងដោយមានការទទួលស្គាល់ថា មានប្រជាពលរដ្ឋមួយភាគធំ ដែលងាយរងគ្រោះដោយសារហានិភ័យផ្សេងៗ អាចរុញច្រានពួកគេឱ្យធ្លាក់ចូលទៅក្នុងរណ្តៅនៃភាពក្រីក្រ ហើយវាជាប្រការមួយធ្វើឱ្យខូចខាតដល់លទ្ធផលនៃការអភិវឌ្ឍន៍ ហើយធ្វើឱ្យចុះខ្សោយនូវកំនើននិងស្ថេរភាពសង្គម។ ប្រទេសកម្ពុជាបានរងនូវវិបត្តិជាប់គ្នាផ្ទួនៗនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ដែលបានបង្កឡើងដោយការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ វិបត្តិសេដ្ឋកិច្ចពិភពលោក និងកត្តាមួយចំនួនទៀតដូចជាព្យុះកេតសាណា ជាដើម។ អាស្រ័យដោយកត្តាទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនក្នុងគោលបំណងកែលំអកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។

តាងនាមឱ្យដៃគូរអភិវឌ្ឍន៍ទាំងឡាយ ខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាលចំពោះកំនើនដែលសម្រេចបានមកទល់នឹងពេលនេះ។ ដោយឡែកក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ (CARD) ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី និងឯកឧត្តម ងី ច័ន្ទ្រផល ដែលទទួលបន្ទុកសម្របសម្រួលការអនុវត្តនេះ បានបង្ហាញនូវភាពជាអ្នកដឹកនាំដ៏រឹងមាំក្នុងការតម្រង់ទិស និងជួយជម្រុញឱ្យមានពង្រាងយុទ្ធសាស្ត្រគាំពារសង្គមជាតិសម្រាប់ជួយដល់ជនក្រីក្រ និងជនងាយរងគ្រោះ (NSPS)នេះឡើង។

សមិទ្ធិផលទាំងនេះ រួមមានការកំណត់វិសាលភាព និងរៀបចំវិធានការគាំពារសង្គមដែលមានស្រាប់ ការរៀបចំវេទិការជាតិក្រោមការណែនាំសម្តេចនាយករដ្ឋមន្ត្រី ទាក់ទងទៅនឹងការងារពង្រឹងប្រព័ន្ធគាំពារសង្គម និងការប្រឹក្សាបច្ចេកទេសដ៏ទូលំទូលាយដើម្បីជូនដំណឹងអំពីយុទ្ធសាស្ត្រនេះទៅដល់ភាគីពាក់ព័ន្ធ រួមមានក្រសួងពាក់ព័ន្ធ ស្ថាប័នថ្នាក់ក្រោមជាតិ សហគមន៍អភិវឌ្ឍន៍

និងសង្គមស៊ីវិល ។ លទ្ធផលដែលបានមក គឺជាយុទ្ធសាស្ត្រពង្រាង ដែលផ្តល់នូវការណែនាំច្បាស់លាស់ឈានទៅសម្រេចបាននូវចក្ខុវិស័យដែល បានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រជាតិដើម្បីអភិវឌ្ឍន៍ និងអាទិភាពអភិវឌ្ឍន៍ប្រទេសជាតិ រួមមាន គោលដៅអភិឌ្ឍន៏សហសវត្សរ៍កម្ពុជាជាដើម ។

បណ្តាដៃគូរអភិវឌ្ឍន៍ សម្តែងនូវការគាំទ្រចំពោះវិធីសាស្ត្រនេះ ហើយជឿជាក់ថាពង្រាងយុទ្ធសាស្ត្រស្តីពីកិច្ចគាំពារសង្គមនេះ មានភាពពាក់ព័ន្ធ និងមានលក្ខណៈសមស្របក្នុងការដោះស្រាយភាពក្រីក្រនិងភាពងាយរងគ្រោះ ហើយជួយពន្លឿនកំនើន សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព នៅកម្ពុជាតាមរយៈការបង្កើនបណ្តាញគាំពារប្រឆាំងនឹងភាពក្រីក្ររ៉ាំរ៉ៃ ភាពអត់ឃ្លាន វិបត្តិ កង្វះខាត និងការមិនរាប បញ្ចូលក្នុងសង្គម ហើយនឹងជួយដល់ការវិនិយោគមូលធនមនុស្ស ។ ការវិនិយោគនៅក្នុងបណ្តាញគាំពារសង្គមសម្រាប់ជនក្រីក្រ និងជន ងាយរងគ្រោះដែលបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រគាំពារសង្គម គឺជាយុទ្ធសាស្ត្រដ៏ឈ្លាសវៃសម្រាប់សង្គមផងនិងសេដ្ឋកិច្ចផង ។

វឌ្ឍនភាពមកទល់នឹងពេលនេះ គឺជាការរទទួលស្គាល់នូវតម្រូវការបន្ទាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ នៅកម្ពុជាតាមរយៈការកែលម្អ និងការពង្រីកកិច្ចគាំពារសង្គម ។ វាបង្ហាញនូវការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការបង្កើតប្រព័ន្ធគាំពារ សង្គមថ្នាក់ជាតិបញ្ចូលគ្នាមួយ ។ វាក៏បង្ហាញឱ្យឃើញនូវកិច្ចសហការរវាងរាជរដ្ឋាភិបាលជាមួយដៃគូរអភិវឌ្ឍន៍ទាំងឡាយ ហើយវាក៏បង្ហាញឱ្យ ឃើញច្បាស់នូវតម្រូវការ និងឱកាសក្នុងការឈានទៅរកការគាំពារសង្គមដ៏កាន់តែទូលំទូលាយថែមទៀតសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ។

***បណ្តាដៃគូរអភិវឌ្ឍន៍ សូមឱ្យមានការឯកភាពឆាប់រហ័សពីរាជរដ្ឋាភិបាល សម្រាប់យុទ្ធសាស្ត្រគាំពារសង្គមជាតិ ។ បណ្តាដៃគូរអភិវឌ្ឍន៍ ប្តេជ្ញាចិត្តធ្វើការជាដៃគូរជាមួយរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអនុវត្តន៍យុទ្ធសាស្ត្រជាតិរបស់ រដ្ឋាភិបាលជាបន្តបន្ទាប់ ។***

ការគាំពារសង្គម គឺជាដំណើរការពហុវិស័យមួយ ។ យ៉ាងហោចណាស់ មានក្រសួងចំនួនដប់ ដែលកំពុងតែអនុវត្តនិងចូលរួម នៅក្នុងអន្តរាគមន៍សម្រាប់ការគាំពារសង្គម[១] ដូចជាដៃគូរអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួនផងដែរ ។

អាស្រ័យហេតុនេះ ដើម្បីឱ្យការអនុវត្តន៏យុទ្ធសាស្ត្រគាំពារសង្គមថ្នាក់ជាតិនេះ ទទួលបានជោគជ័យ យើងនឹងត្រូវពឹងផ្អែកទៅលើការ សម្របសម្រួលគ្នា ប្រកបដោយប្រសិទ្ធភាព រវាងបណ្តាដៃគូរអភិវឌ្ឍន៏និងបណ្តាក្រសួងដែលពាក់ព័ន្ធ ។ ការសម្របសម្រួល គឺជាការចាំបាច់ក្នុងការជៀសវាង ភាពត្រួតគ្នា ឬចន្លោះប្រហោងណាមួយទាំងផ្នែកប្រធានបទនិងផ្នែកភូមិសាស្ត្រ

---

[១] រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកិច្ចការនារី ។ ក្រសួងផែនការ ក៏មានតួនាទីសំខាន់នៅក្នុងអត្តសញ្ញាណកម្មជនក្រីក្រផងដែរ ។

តែជួយធ្វើសុខដុមនីយកម្មលើនីតិវិធីអនុវត្ត ព្រមទាំងធានា នូវការប្រើប្រាស់មូលនិធិដែលបានមកពីថវិកាជាតិ និងពីបណ្តាដៃគូរអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ សកម្មភាពសម្របសម្រួល ត្រូវរួមបញ្ចូលនូវការពិនិត្យមើលគោលនយោបាយ ការត្រួតពិនិត្យតាមដានការវិវឌ្ឍន៍ជាក់ស្តែង ក៏ដូចជាការវាយតម្លៃលើលទ្ធផលទូទៅ ការគ្រប់គ្រងចំណេះដឹងនិងព័តិមាន ការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ និងយន្តការកំណត់គោលដៅសមស្រប។ ការរៀបចំ ស្ថាប័នឱ្យបានសមស្រប សម្រាប់សម្របសម្រួល និងធានាភាពគ្រប់គ្រាន់ដែលបំពេញឱ្យយុទ្ធសាស្ត្រវិស័យសង្គមកិច្ចដែលមានស្រាប់ គឺជាការសំខាន់ណាស់សម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រគាំពារសង្គមថ្នាក់ជាតិប្រកបដោយជោគជ័យ។

***បណ្តាដៃគូរអភិវឌ្ឍន៍ ស្វាគមន៍ចំពោះការណែនាំរបស់រាជរដ្ឋាភិបាល ទាក់ទងនឹងការរៀបចំជាស្ថាប័ន សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិ។***

ប្រសិទ្ធភាពនៃប្រព័ន្ធគាំពារសង្គមជាតិ ត្រូវពឹងផ្អែកទៅលើហិរញ្ញប្បទានប្រកបដោយនិរន្តរភាព សម្រាប់ការសម្របសម្រួលការកំណត់គោលដៅជនក្រីក្រនិងជនងាយរងគ្រោះ អត្ថប្រយោជន៍ និងការផ្តល់សេវាកម្ម។ បណ្តាដៃគូអភិវឌ្ឍន៍ សូមគាំទ្រចំពោះការធ្វើឱ្យកម្មវិធីគាំពារសង្គមនេះ មានលក្ខណៈសុខដុមនីយកម្ម និងតម្រឹម ហើយសូមត្រៀមរួចជាស្រេច ក្នុងការគាំទ្រដល់វិធីសាស្ត្រណែនាំរបស់រដ្ឋាភិបាលដើម្បីអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមនេះ ។

***បណ្តាដៃគូរអភិវឌ្ឍន៍ សូមស្វាគមន៍ចំពោះការចង្អុលបង្ហាញពីរាជរដ្ឋាភិបាល ទាក់ទងនឹងការកំណត់អាទិភាពធនធានរដ្ឋាភិបាលដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ និងវិធីសាស្ត្រដែលដៃគូរអភិវឌ្ឍន៍ អាចជួយសម្រួលដល់ការស្រាវជ្រាវរកវិធីសាស្ត្រសម្រាប់ការគាំពារសង្គម។***

ការកំណត់អាទិភាពអន្តរាគមន៍សម្រាប់ការគាំពារសង្គមរយៈពេលខ្លី នឹងអាស្រ័យដោយទំហំសារពើព័ន្ធ សមត្ថភាពមានកម្រិត និងសមត្ថភាពស្រូបយក។ ជំហានបន្ទាប់មកទៀត ដើម្បីប្រតិបត្តិយុទ្ធសាស្ត្រនេះ ត្រូវធ្វើ :

i. កម្មវិធីកសាងសមត្ថភាព សំរាប់ យន្តការសម្របសម្រួលដល់ការគាំពារសង្គម នៅពេលយន្តការបានបង្កើត
ii. ការប៉ាន់ស្មានតម្រូវការសមត្ថភាពមុខងារសម្រាប់កម្មវិធីនីមួយៗ នៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ/សង្កាត់
iii. សុខុដុមនីយកម្ម និងពង្រីកកម្មវិធីដែលមានស្រាប់
iv. រៀបចំគម្រោងបច្ចេកទេសសម្រាប់កម្មវិធីថ្មីៗ ឬកម្មវិធីពង្រីកបន្ថែម ដូចជាការផ្ទេរសាច់ប្រាក់ និងការងារសាធារណៈ
v. ការវាយតម្លៃអំពីផលប៉ះពាល់ភាពក្រីក្រនៃ វិធានការគាំពារសង្គមមានស្រាប់ និងវិធានការគាំពារសង្គមថ្មី

ដៃគូរអភិវឌ្ឍន៍ ត្រៀមរួចជាស្រេច ក្នុងការជួយជ្រោមជ្រែងនៅតាមដំណាក់កាលនីមួយៗទាំងនេះ។ យើងក៏សូមអះអាងជាថ្មីអំពីការបន្តគាំទ្ររបស់យើងទៅលើសកម្មភាពបណ្តាញសុវត្ថិភាពសង្គមដែលមានស្រាប់ ដែលផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្របំផុតនិងជនងាយរងគ្រោះបំផុតរួមទាំងមូលនិធិសមធម៌សុខភាព កម្មវិធីអាហារូបករណ៍ អាហារូបត្ថម្ភនៅតាមសាលារៀន ការងារសាធារណៈ ការពង្រឹងយន្តការឆ្លើយតបទៅនឹងវិបត្តិនិងគ្រោះមហន្តរាយ និងការពង្រីកវិសាលភាពកម្មវិធីអត្តសញ្ញាណកម្មជនក្រីក្រ។

***បណ្តាដៃគូរអភិវឌ្ឍន៍ ស្វាគមន៍ចំពោះការណែនាំពីរាជរដ្ឋាភិបាល អំពីតម្រូវការអាទិភាព សម្រាប់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស ជាពិសេសការកសាងសមត្ថភាពស្ថាប័នដើម្បីគ្រប់គ្រងនិងចាត់ចែងការគាំពារសង្គមនៅកម្ពុជា ។***

ក្នុងនាមដៃគូរអភិវឌ្ឍន៍ ខ្ញុំសូមអបអរសាទររាជរដ្ឋាភិបាលជាថ្មីម្តងទៀត ចំពោះវឌ្ឍនភាពគួរឱ្យកត់សំគាល់យ៉ាងច្រើនក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ និងត្រៀមជានិច្ចក្នុងការគាំទ្រដល់ការអនុវត្តន៍យុទ្ធសាស្រ្តជាតិនិងពង្រីកវិសាលភាពគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅព្រះរាជាណាចក្រកម្ពុជា ។